ព្រះរាជាណាចក្រកម្ពុជា

**តុលាការកំពូល** **ជាតិ សាសនា ព្រះមហាក្សត្រ**

សំណុំរឿងរដ្ឋប្បវេណី

លេខ: ៣៣៩ប្រ

ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៣ **នាមនាមប្រជារាស្ត្រខ្មែរ**

**សាលដីកា** **តុលាការកំពូល**

លេខ : ២៧៨ បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៤

ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ឌិត** | **មុន្ទី** | ជាប្រធាន |
| ២-លោក | ជីវ | កេង | ជាចៅក្រមរបាយការណ៍ |
| ៣-លោក | ប្រាក់ | គឹមសាន | ជាចៅក្រម |
| ៤-លោក | ឈឹម | ស៊ីផល | ជាចៅក្រម |
| ៥-លោក | យូរ | ឧត្តរា | ជាចៅក្រម |

**ក្រឡាបញ្ជី**

កញ្ញា ហុក សុខធុល

**តំណាងមហាអយ្យការ**

លោក ឈួន ចាន់ថា ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្ដឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ១៨២"ឈ" ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០២ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៤៤១ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះ **ឡៅ ចិន្ដូរ្យ** (ជាចុងបណ្ដឹងសាទុក្ខ) ភេទប្រុស អាយុ៥៦ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃផ្ទះលេខ ៤៦ ផ្លូវលេខ៦០៨ សង្កាត់បឹងកក់២ ខណ្ឌទួលគោក ក្រុងភ្នំពេញ។

ចុងចំលើយឈ្មោះ**ម៉ម យ៉ូសែមឡៀវ** (ជាម្ចាស់បណ្ដឹងសាទុក្ខ) ទីលំនៅផ្ទះលេខ ១ ផ្លូវ ៦០៦ សង្កាត់បឹងកក់២ ខណ្ឌទួលគោក ក្រុងភ្នំពេញ ។

តតិយជន លោក MICHAEL WAYNE COLLINS (ម្ចាស់បណ្ដឹងសាទុក្ខ) ភេទប្រុស អាយុ៥៤ឆ្នាំ កាន់លិខិតឆ្លងដែនសហរដ្ឋអាមេរិកលេខ ២០០៥៩២៤០១ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ ១៩៩៩ ។

ផ្ទេរសិទ្ធិឱ្យលោក លឹម ស៊ុនលី ។

មានមេធាវី លោក ហុង គីមសួន ។

**ចម្ងល់ចំណុចរឿង** : ប្តឹងជំទាស់នឹងការអនុវត្តសាលក្រម .

បានឃើញបណ្តឹងសាទុក្ខលេខ ៤០៣ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០២ របស់ឈ្មោះ នុត ទីតួ មេធាវីតំណាងលោក MICHAEL WAYNE COLLINS ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១៨២"ឈ"ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៣៣៥ប្រ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៣ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១៩-៧-២០០០ របស់ដើមចោទ ឈ្មោះឡៅ ពិទូរ្យ បានប្តឹងសុំបដិសេធរាល់កិច្ចសន្យាទាំងឡាយ ដែលទាក់ទិននឹងការផ្ទេរសិទ្ធិផ្ទះលេខ៣១១ ផ្លូវ ២៧១ សង្កាត់ទំនប់ទឹក ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ដែលមានក្បាលដីលេខ ៣ សន្លឹកលេខ១០៤ វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១៩៥០២ រវាងខ្លួន (ឡៅ ពិទូរ្យ) និងចុងចម្លើយឈ្មោះ ច័ន្ទ យ៉ូសែបឆៀវ ដោយសំអាងហេតុថា : កាលពីថ្ងៃទី១៥-១០-១៩៩៩ ខ្លួនបានផ្តិតមេដៃលើឯកសារចំនួន០៩ច្បាប់ ដោយពុំបានដឹងពីអត្ថន័យ ឬខ្លឹមសារនៅក្នុងឯកសារនោះទេ លុះពេលខ្លួនត្រឡប់មកពីសហរដ្ឋអាមេរិកវិញ ទើបដឹងថា ការផ្តិតមេដៃលើឯកសារចំនួន ៩ច្បាប់ នោះទាក់ទិននឹងការទិញ លក់ ផ្ទះលេខ ៣១១ ខាងលើ ដែលតាមការពិតខ្លួនមិនបានលក់ផ្ទះលេខ ៣១១ នោះសោះឡើយ ។ ហើយពាក្យបណ្តឹងនេះ ត្រូវបានតុលាការក្រុងភ្នំពេញ លើកមកជំនុំជំរះនិងសំរេចសេចក្តីចប់សព្វគ្រប់ ហើយតាមអំណាចសាលក្រមស្ថាពរលេខ ៨០"ខ"ចុះថ្ងៃទី២១-៨-២០០១ ដោយបដិសេធចោលជាអសារបង់នូវរាល់កិច្ចសន្យា ឬលិខិតស្នាមដែលទាក់ទិននឹងការទិញ-លក់ ផ្ទះលេខ ៣១១ ខាងលើរវាងឈ្មោះឡៅ ពិទូរ្យ និងឈ្មោះច័ន្ទ យ៉ូសែបឆៀវ ហើយសំរេចប្រគល់ផ្ទះលេខ ៣១១ នេះ ឱ្យទៅជាកម្មសិទ្ធិរបស់ក្រុមជំនុំយូរ៉ៃណៃធីតមេថូឌីស្ទ វិញ ដែលមានឈ្មោះឡៅ ពិទូរ្យ ជាតំណាង ។

ប៉ុន្តែនៅពេលអនុវត្តសាលក្រមស្ថាពរលេខ ៨០"ខ" ចុះថ្ងៃទី២១-៨-២០០១ ខាងលើស្រាប់តែមានឈ្មោះ MICHAEL WAYNE COLLINS (ភតិយជន) ដែលមានលោកនុត ទីតួជាមេធាវីតំណាងចេញមុខប្តឹងជំទាស់ដោយលើកសំអាងហេតុថា ឈ្មោះឡៅ ពិទូរ្យ មិនមែនជាតំណាងរបស់ក្រុមជំនុំយូណៃធីតមេថូឌីស្ទ នោះឡើយ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៨០"ខ"ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០១ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី១៩-៧-២០០០ របស់ដើមចោទឈ្មោះឡៅ ពិទូរ្យ

ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-បដិសេធចោលជាអសារបង់នូវរាល់កិច្ចសន្យា ឬលិខិតស្នាមដែលទាក់ទងនឹងការទិញលក់ផ្ទះលេខ ៣១១ ក្បាលដីលេខ ៣ សន្លឹកលេខ ១០៤ ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១៩៥០២ ចុះថ្ងៃទី២៥-៣-១៩៩៥ ស្ថិតនៅផ្លូវលេខ ២៧១ សង្កាត់ទំនប់ទឹក ខ័ណ្ឌចំការមន ក្រុងភ្នំពេញ រវាងឈ្មោះឡៅ ពិទ្យូ និងឈ្មោះច័ន្ទ យ៉ូសែមធៀរ ។

៣-ប្រគល់ផ្ទះលេខ ៣១១ ស្ថិតនៅផ្លូវលេខ ២៧១ សង្កាត់ទំនប់ទឹក ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១៩៥០២ ចុះថ្ងៃទី២៥-៣-១៩៩៥ ឱ្យទៅជាកម្មសិទ្ធិរបស់ពួកជំនុំយូណៃធីតមេថូឌីសវិញ ដែលមានឈ្មោះឡៅ ពិទ្យូ ជាតំណាង ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីសរុបចំនួន ៧.០០០៛ ដែលមេធាវីឈួង ចាន់ថន ជាតំណាងដើមចោទបានបង់រួចហើយ កាលបើហួសកំណត់ប្តឹងឧទ្ធរណ៍ ត្រូវបង្គាប់ឱ្យឈ្មោះច័ន្ទ យ៉ូសែមធៀរ បង់សងទៅតំណាងដើមចោទវិញ ។

៥-សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខតំណាងដើមចោទនិងតំណាងចុងចម្លើយ ។ បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០០១ របស់ឈ្មោះ MICHAEL WAYNE COLLINS ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ៨០"ខ"ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០១ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចសាលក្រមទាំងមូល ។

បានដីកាសំរេចលេខ ៥២១ ចុះថ្ងៃទី០១ ខែមិនា ឆ្នាំ២០០២ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលស្គាល់ឈ្មោះសុខសុវណ្ណឌី ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅភូមិព្នៅ ឃុំតាសួស ស្រុកស្វាយរៀង ខេត្តស្វាយរៀង ជាតំណាងស្របច្បាប់របស់ក្រុមជំនុំយូណៃធីតមេថូឌីសក្នុងការកាន់កាប់គ្រប់គ្រងផ្ទះលេខ ៣១១ ស្ថិតនៅផ្លូវលេខ ២៧១ សង្កាត់ទំនប់ទឹក ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១៩៥០២ ចុះថ្ងៃទី២៥-៣-១៩៩៥ ជំនួសក្រុមជំនុំយូណៃធីតមេថូឌីសចាប់ពីថ្ងៃនេះតទៅ ។

២-សេចក្តីសំរេចនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០២ របស់ឈ្មោះឡៅ ពិទ្យូ ប្តឹងមិនសុខចិត្តនឹងដីកាសំរេចលេខ ៥២១ ចុះថ្ងៃទី០១ ខែមិនា ឆ្នាំ២០០២ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១៤០"ឈ"ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២២-៥-២០០២ របស់ឈ្មោះឡៅ ពិទ្យូ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-បដិសេធដីកាសំរេចលេខ ៥២១ ចុះថ្ងៃទី០១-៣-២០០២ របស់តុលាការក្រុងភ្នំពេញចោលជាអសារបង់ ។

៣-ទទួលស្គាល់លោក ឡៅ ពិទ្យូ ភេទប្រុស អាយុ៥៦ឆ្នាំ ទីលំនៅសព្វថ្ងៃផ្ទះលេខ ៤៦ ផ្លូវលេខ ៦០៨ សង្កាត់បឹងកក់២ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ជាតំណាងស្របច្បាប់ ក្នុងការគ្រប់គ្រងផ្ទះលេខ ៣១១ ផ្លូវលេខ ២៧១ សង្កាត់ទំនប់ទឹក ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ជំនួសឱ្យក្រុមជំនុំឃ្មៃណៃធីត មេថូឌីស្ទ ប្រចាំនៅកម្ពុជា តាមសាលក្រមរដ្ឋប្បវេណីស្ថាពរលេខ ៨០"ខ" ចុះថ្ងៃទី២១-៨-២០០១ របស់តុលាការក្រុងភ្នំពេញ ។

៤-បង្គាប់ឱ្យក្រុមអនុវត្តសាលក្រមនៃតុលាការក្រុងភ្នំពេញ បន្តអនុវត្តសាលក្រមស្ថាពរលេខ ៨០"ខ" ចុះថ្ងៃទី២១-៨-២០០១ របស់តុលាការក្រុងភ្នំពេញជាបន្តទៅទៀត ។

៥-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ៤៤១ ចុះថ្ងៃទី០៨-៧-២០០២ របស់សាលាឧទ្ធរណ៍ទៅតុលាការក្រុងភ្នំពេញវិញ ដើម្បីអនុវត្តន៍ ។

៦-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ ដែលដើមបណ្តឹងបានបង់រួចហើយ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្វ៊ីង ២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០៛ ចំណាយលើអាជ្ញាតុលាការ ៥.០០០៛ សរុប ១៣.០០០៛ ។

៧-សាលដីកានេះ ជំនុំជំរះជាសាធារណៈនៅថ្ងៃទី០៦-៨-២០០២ ចំពោះមុខមេធាវីតំណាងដើមបណ្តឹងឧទ្ធរណ៍ កំបាំងមុខចុងបណ្តឹងឧទ្ធរណ៍ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៨-៨-២០០២ចំពោះមុខឈ្មោះឡៅ ពិទ្យូ កំបាំងមុខចុងបណ្តឹងឧទ្ធរណ៍ បើកផ្លូវតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ ១៣៧ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០២ របស់ឈ្មោះនុត ទីតូ ជាមេធាវីការពារឱ្យតតិយជន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១៤០"ឈ"ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសាលដីកាទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១៨២"ឈ" ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់របស់លោកមេធាវីនុត ទីតូ ចុះថ្ងៃទី០៣-៩-២០០២ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តំកល់សាលដីកាកំបាំងមុខលេខ ១៤០"ឈ"ចុះថ្ងៃទី០៨-៨-២០០២ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី និងមាន

ប្រសិទ្ធិភាពអនុវត្តភ្លាមៗ ទោះបីមានបណ្តឹងសាទុក្ខក៏ដោយ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៤០៣ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០២ របស់ឈ្មោះ នុត ទីតួ មេធាវីតំណាងលោក MICHAEL WAYNE COLLINS ប្តឹងមិនសុខចិត្តនឹងសាលដីការជ្ជវេណីលេខ ១៨២"ឈ"ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីការជ្ជប្បវេណីលេខ ១៨២"ឈ"ចុះថ្ងៃទី០៣-១០-២០០២ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈខុសឆ្គងទាំងទំរង់ និងគតិច្បាប់ហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះ សំរេចតាមច្បាប់ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ហុង គឹមសួន ជាមេធាវីការពារឱ្យតតិយជន បានលើកឡើងថា : ខ្លួនសូមឯកភាពទៅតាមរបាយការណ៍របស់ចៅក្រមរបាយការណ៍ ព្រោះថា សាលាឧទ្ធរណ៍បានសំរេចនេះ ធ្វើឱ្យខូចប្រយោជន៍កូនក្តីខ្លួន ព្រោះថា លោក ឡៅ ពិទូរ្យ គ្រាន់តែជាតំណាងកាន់កាប់អចលនវត្ថុតែប៉ុណ្ណោះ ពុំមែនជាម្ចាស់កម្មសិទ្ធិករនៃអចលនវត្ថុនេះទេ លោកឡៅ ពិទូរ្យនេះ ត្រូវបានព្រះវិហារសាសនាគ្រីស្ទ របស់ក្រុមជំនុំឃ្មូណៃធីតមេថូឌីស្ទ ដកសេចក្តីទុកចិត្ត ហើយទទួលស្គាល់តំណាងថ្មីជំនួស ដោយលោកសុខ សុវណ្ណឌី ។ ខ្លួនសុំសំណូមពរ ឯកឧត្តមប្រធាន មេត្តាតំកល់សេចក្តីសំរេចរបស់តុលាការក្រុងភ្នំពេញ ជាបន្តទៅទៀត ព្រោះនៅខាងក្រោមនេះ មានរឿងច្រើនណាស់ ដែលត្រូវដោះស្រាយ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីតតិយជន
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ៤០៣ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០២ របស់លោកនុត ទីតួ ជាមេធាវីលោក MICHAEL WAYNE COLLINS ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចទទួលស្គាល់លោក ឡៅ ពិទូរ្យ ជាតំណាងស្របច្បាប់ក្នុងការគ្រប់គ្រងផ្ទះទំនាស់ជំនួសក្រុមជំនុំឃ្មូណៃធីតមេថូឌីស ប្រចាំកម្ពុជាតាម

សាលក្រមរដ្ឋប្បវេណីលេខ ៨០"ខ"ចុះថ្ងៃទី២១-៨-២០០១ របស់តុលាការក្រុងភ្នំពេញ ដោយអាងហេតុថា លោកឡៅ ពិទ្ធ្យ នៅតែជាតំណាងស្របច្បាប់របស់ក្រុមជំនុំយូណៃធីតមេថូឌីសនៅកម្ពុជាដដែល ហើយវាគ្មានឯកសារណាបញ្ជាក់ថា ក្រុមជំនុំនេះស្ថិតនៅក្រោមពី GBGM ទេនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះថា :

. តាមចំណុច៣ នៃលិខិតជាស្គង់ដា មានកិច្ចព្រមព្រៀងជាមួយសាសនទូតចុះថ្ងៃទី០៤-១២-១៩៩៧ លោកឡៅ ពិទ្ធ្យ មានអាណត្តិនៅប្រទេសកម្ពុជា តែ៣ឆ្នាំប៉ុណ្ណោះ គឺពីថ្ងៃទី០១-១២-១៩៩៧ ដល់ថ្ងៃទី០១-១២-២០០០ ។

. តាមលិខិតចុះថ្ងៃទី០២-១០-២០០១ លេខាធិការប្រតិបត្តិតំបន់អាស៊ីប៉ាស៊ីហ្វិកខាងកើតរបស់អង្គការ GENERAL BOARD OF GLOBAL MINISTRIES នៃក្រុមជំនុំយូណៃធីតមេថូឌីស្ទ បានបញ្ជាក់ថា បានតែតាំងលោក MICHAEL COLLINS ជានាយកប្រតិបត្តិប្រចាំប្រទេស នៃក្រុមជំនុំយូណៃធីតមេថូឌីស ប្រចាំព្រះរាជាណាចក្រកម្ពុជាហើយ ។

. តាមរបាយការណ៍ស្តីពីការចុះបេសកកម្មនៅកម្ពុជា និងការឈប់បំរើការងារ GBGM ចុះថ្ងៃទី១៨-៣-២០០០ របស់លោកឡៅ ពិទ្ធ្យ តាមកិច្ចសន្យាទិញ លក់ផ្ទះទំនាស់ តាមចម្លើយលោកឡៅ ពិទ្ធ្យ នៅមុខតុលាការក្រុងភ្នំពេញ បញ្ជាក់ថា លោកឡៅ ពិទ្ធ្យ ពិតជាតំណាងGBGM ប្រាកដមែន ។

ដូច្នេះលោកឡៅ ពិទ្ធ្យពុំមានសិទ្ធិមកទាមទារយកផ្ទះទំនាស់នេះ ទៅកាន់កាប់គ្រប់គ្រងជាកម្មសិទ្ធិផ្ទាល់ខ្លួនបន្តទៀតទេ នៅពេលដែលលោកអស់អាណត្តិពីក្រុមជំនុំយូណៃធីតមេថូឌីស្ទ ប្រចាំនៅកម្ពុជាហើយនោះ ។

- យល់ឃើញថា តុលាការកំពូលបានកោះហៅលោកឡៅ ពិទ្ធ្យ និងលោក លឹមស៊ុនលី ជាតំណាងរបស់លោក MICHAEL WAYNE COLLINS មកចូលរួមនាសវនាការនេះហើយ ប៉ុន្តែលោកឡៅ ពិទ្ធ្យ បានផ្លាស់ប្តូរលំនៅទៅហើយ រកពុំឃើញទេ រីឯលោកលឹម ស៊ុនលី ពុំបានមកចូលរួមមែន ប៉ុន្តែមេធាវីរបស់លោកបានមកចូលរួមហើយ ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ១៨២"ឈ" ចុះថ្ងៃទី០៣ខែតុលា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីកំបាំងមុខលោកឡៅ ពិទ្ធ្យ និងធនិយជន ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១-ទទួលបណ្តឹងសាទុក្ខលេខ៤០៣ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០២ របស់លោកមេធាវីនុត ទីតូ ទុកជាត្រឹមត្រូវតាមទំរង់និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ១៨២"ឈ" ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ទាំងមូល ដោយឥតបង្វិល ។

៣-ទទួលស្គាល់លោកMICHAEL WAYNE COLLINS ជាតំណាងនៃក្រុមជំនុំយូណៃធីតមេថូឌីស្ទ ប្រចាំព្រះរាជាណាចក្រកម្ពុជា ជាអ្នកមានសិទ្ធិគ្រប់គ្រងផ្ទះលេខ ៣១១ ផ្លូវ២៧១ សង្កាត់ទំនប់ទឹក ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ជំនួសលោក ឡៅ ពិទូរ្យ ដែលបានចប់អាណត្តិតាមសាលក្រមរដ្ឋប្បវេណីស្ថាពរលេខ ៨០"ខ" ចុះថ្ងៃទី២១-៨-២០០១ របស់តុលាការក្រុងភ្នំពេញ ។

៤-បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ ៣៣៥ប្រ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៣ របស់តុលាការកំពូល ទៅតុលាការក្រុងភ្នំពេញ ដើម្បីបន្តអនុវត្តសាលក្រមរដ្ឋប្បវេណីលេខ ៨០"ខ" ចុះថ្ងៃទី២១-៨-២០០១ ដែលមានលោក MICHAEL WAYNE COLLINS ជាតំណាងវិញ ។

៥-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០៛ ដែលតតិយជន បានបង់ គឺ :

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្លឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់.

-ចំណាយលើការប្រគល់ដីកាកោះចំនួន ១៥.០០០៛ សរុប ១៩.០០០៛ ហើយតម្រូវអោយលោកឡៅ ពិទូរ្យ សងប្រាក់ ១៩.០០០៛ នេះទៅតតិយជនវិញ ។

៦-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០២ ខែ ធ្នូ ឆ្នាំ២០០៤ ។